# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**សាលាដំបូងខេត្តកណ្ដាល**

-សំណុំរឿងព្រហ្មទណ្ឌលេខៈ ១៣៧៣ អក
ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១៧
-សាលក្រមលេខៈ **៩៤** (យ)
ចុះថ្ងៃទី២៤ ខែសីហា ឆ្នាំ២០២២

## តាងនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងខេត្តកណ្ដាល

-បានបើកសវនាការជំនុំជម្រះជាអសាធារណៈ នៅសាលាដំបូងខេត្តកណ្ដាល នៅថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០២២ ដោយមាន សមាសភាពដូចតទៅ:

### ក្រុមប្រឹក្សាជំនុំជំរះ

លោកស្រី [redacted] ប្រធានក្រុមប្រឹក្សា
លោក [redacted] ចៅក្រុមប្រឹក្សា
លោក [redacted] ចៅក្រុមប្រឹក្សា

### តំណាងអយ្យការ

លោក [redacted] ព្រះរាជអាជ្ញារង អមសាលាដំបូងខេត្តកណ្ដាល

### ក្រឡាបញ្ជីសវនាការ

លោកស្រី [redacted] ក្រឡាបញ្ជី សាលាដំបូងខេត្តកណ្ដាល

ដើម្បីជំនុំជម្រះបណ្ដឹងទាស់លើសាលក្រមលេខៈ ៩៦ (យ) ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០១៨ សំណុំរឿងព្រហ្មទណ្ឌលេខៈ **១៣៧៣ អក** ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១៧ ដែលមានពិរុទ្ធជនដូចខាងក្រោម ៖

-ឈ្មោះ [redacted] ម៉ូ ភេទប្រុស អាយុ ១៦ឆ្នាំ ជនជាតិខ្មែរ មុខរបរកសិករ ទីកន្លែងកំណើត និងទីលំនៅបច្ចុប្បន្ននៅ[redacted] ខេត្តកណ្ដាល ឪពុកឈ្មោះ [redacted] ព្រិល (រ) ម្ដាយឈ្មោះ[redacted] សឿន (ស) នៅលីវ។ (ឃុំខ្លួនថ្ងៃទី០២ ខែមីនា ឆ្នាំ២០២២)

អមដោយលោក [redacted] ជាមេធាវីការពារសិទ្ធិឱ្យពិរុទ្ធជន ។

ជាប់ចោទពីបទ: រំលោភសេពសន្ថវៈ ប្រព្រឹត្តនៅភូមិព្រែកតាកូវ ឃុំព្រែកតាកូវ ស្រុកខ្សាច់កណ្ដាល ខេត្តកណ្ដាល កាលពីថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១៧ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា ២៣៩ និងមាត្រា ២៤០ នៃក្រមព្រហ្មទណ្ឌ ។

-ដើមបណ្ដឹងរដ្ឋប្បវេណី ឈ្មោះ[redacted] តែ ហៅ ស្រីម៉ៅ ភេទស្រី អាយុ ១៩ឆ្នាំ ជនជាតិ ខ្មែរ មុខរបរកម្មការិនីរោងចក្រ ទីកន្លែងកំណើត និងទីលំនៅបច្ចុប្បន្នស្នាក់នៅភូមិត្រពាំងក្រសាំង ឃុំក្រៀមក្សាន ស្រុកឧត្តុង្គ ខេត្តកំពង់ស្ពឺ ឪពុកឈ្មោះ[redacted] ខ្លី (រ) ម្ដាយឈ្មោះ[redacted] តុក (រ) នៅលីវ ។

### អង្គហេតុមានដូចតទៅ

កាលពីដើមខែតុលា ឆ្នាំ២០១៧ ឈ្មោះ [redacted] នៅ បានស្គាល់និងទាក់ទងស្រលាញ់គ្នាជាមួយឈ្មោះ [redacted] តែ ភេទស្រី លុះដល់ថ្ងៃទី២១ ខែតុលា ឆ្នាំ២០១៧ ឈ្មោះ [redacted] តែ បានទូរស័ព្ទទៅឈ្មោះ [redacted] នៅ ណាត់គ្នាដើរលេង ហើយឈ្មោះ [redacted] នៅ ក៏បានមកយកឈ្មោះ [redacted] តែ ដែលមកជាមួយឈ្មោះ [redacted] សីលា ហើយបានដឹកគ្នាទៅផ្ទះរបស់ឈ្មោះ [redacted] ឈុនលី ដែលនៅភូមិព្រែកតាកូវ ពេលទៅដល់ឈ្មោះ [redacted] នៅ បានទុកឈ្មោះ [redacted] តែ អោយនៅផ្ទះរបស់ឈ្មោះ [redacted] សីលា ហើយឈ្មោះ [redacted] នៅ បានទៅទិញគ្រឿងញៀនយកមក



Scanned with CamScanner

សម្រាប់ជក់ លុះទិញថ្នាំបានហើយក៏បាននាំគ្នាជក់រួមមានឈ្មោះ [redacted] នៅ , ឈ្មោះ [redacted] ឈុនលី , ឈ្មោះ [redacted] ម៉ូ , ឈ្មោះ [redacted] សីលា , ឈ្មោះ [redacted] វ័ត្ត និងឈ្មោះ ខ្វី តែ ពេលជក់ហើយនៅម៉ោង ២០ ស្រាប់តែអ្នកទាំងប្រាំ ខាងលើបាននាំគ្នាចាប់រំលោភឈ្មោះ [redacted] តែ បានសម្រេចគ្រប់គ្នា លុះដល់ថ្ងៃទី២២ ខែតុលា ឆ្នាំ២០១៧ ម៉ោង ២២ ឈ្មោះ [redacted] នៅ , ឈ្មោះ [redacted] សីលា , ឈ្មោះ [redacted] ឈុនលី , ឈ្មោះ [redacted] ម៉ូ និងឈ្មោះ [redacted] វ័ត្ត បានធ្វើសកម្មភាពចាប់រំលោភលើឈ្មោះ [redacted] តែ ម្តងទៀតហូតបានសម្រេចគ្រប់គ្នា ក្រោយទទួលពាក្យបណ្តឹងសមត្ថកិច្ចបានទៅឃាត់ខ្លួនបានចំនួនពីរនាក់ដែលមានឈ្មោះ [redacted] សីលា និងឈ្មោះ [redacted] ឈុនលី ចំណែកបីនាក់ទៀតបានរត់គេចខ្លួនបាត់ ។

**បានឃើញ** សាលក្រមលេខ: ៩៦ (ឃ) ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០១៩ របស់សាលាដំបូងខេត្តកណ្តាលដែលមានខ្លឹមសារ ៖

១-ផ្តន្ទាទោសលើជនជាប់ចោទ ៖

ក-ឈ្មោះ [redacted] សីលា ភេទប្រុស អាយុ ២៤ឆ្នាំ ដាក់ពន្ធនាគារកំណត់រយៈពេល ០៥ (ប្រាំ) ឆ្នាំ តែអនុវត្តទោសក្នុងពន្ធនាគារ ០១ (មួយ) ឆ្នាំ ទោសនៅសល់ត្រូវព្យួរធម្មតា ។

ខ-ឈ្មោះ [redacted] ឈុនលី ភេទប្រុស អាយុ ១៧ឆ្នាំ ដាក់ពន្ធនាគារកំណត់រយៈពេល ០២ (ពីរ) ឆ្នាំ តែអនុវត្តទោសក្នុងពន្ធនាគារ ០១ (មួយ) ឆ្នាំ ទោសនៅសល់ត្រូវព្យួរធម្មតា ។

គ-ឈ្មោះ [redacted] វ័ត្ត ភេទប្រុស អាយុ ២២ឆ្នាំ ដាក់ពន្ធនាគារកំណត់រយៈពេល ០៥ (ប្រាំ) ឆ្នាំ ។

ឃ-ឈ្មោះ [redacted] នៅ ភេទប្រុស អាយុ ២០ឆ្នាំ ដាក់ពន្ធនាគារកំណត់រយៈពេល ០៥ (ប្រាំ) ឆ្នាំ

ង-ឈ្មោះ [redacted] ម៉ូ ភេទប្រុស អាយុ ១៦ឆ្នាំ ដាក់ពន្ធនាគារកំណត់រយៈពេល ០២ (ពីរ) ឆ្នាំ ០៦ (ប្រាំមួយ) ខែ ។

ពីបទ: **រំលោភសេពសន្ថវៈ** ប្រព្រឹត្តនៅភូមិព្រែកតាកូវ ឃុំព្រែកតាកូវ ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល កាលពីថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១៧ ផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ២៣៩ និងមាត្រា ២៤០ នៃក្រមព្រហ្មទណ្ឌ ។

២-បង្គាប់ឱ្យចាប់ និងឃុំខ្លួនលើឈ្មោះ [redacted] វ័ត្ត , ឈ្មោះ [redacted] នៅ និងឈ្មោះ [redacted] ម៉ូ មកដាក់ពន្ធនាគារខេត្តកណ្តាលគិតពីថ្ងៃចាប់ខ្លួនបាន ។

-សាលក្រមនេះជំនុំជំរះជាសារធារណៈនៅថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០១៨ និងប្រកាសជាសាធារណៈនៅថ្ងៃទី១៩ ខែតុលា ឆ្នាំ២០១៨ ចំពោះមុខជនជាប់ចោទឈ្មោះ ឡូ សីលា និងឈ្មោះ ផុន ឈុនលី និងកំបាំងមុខដើមបណ្តឹងរដ្ឋប្បវេណី និងជនជាប់ចោទឈ្មោះ [redacted] វ័ត្ត , ឈ្មោះ [redacted] នៅ និងឈ្មោះ [redacted] ម៉ូ ទុកសិទ្ធិឱ្យប្តឹងទាស់ ប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។

**បានឃើញ** ពាក្យសុំប្តឹងទាស់លេខ: ០៣១ ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១៩ របស់ឈ្មោះ [redacted] វ័ត្ត ដែលមានខ្លឹមសារ:

"សុំប្តឹងទាស់ និងសាលក្រមព្រហ្មទណ្ឌកំបាំងមុខលេខ: ៩៦ (ឃ) ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ ២០១៨ របស់សាលាដំបូងខេត្តកណ្តាល ។

## **នាពេលសវនាការ**

-ពិរុទ្ធជនឈ្មោះ [redacted] ម៉ូ បានឆ្លើយថា ខ្លួនសុំប្តឹងទាស់នឹងសាលក្រមកំបាំងមុខលេខ ៩៦ "ឃ" ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០១៨ ព្រោះខ្លួនមិនសុខចិត្តនឹងសេចក្តីសម្រេចដែលមាននៅក្នុងសាលក្រមនោះ។



Scanned with CamScanner

ការផ្តន្ទាទោសនេះ មានលក្ខណៈធ្ងន់ធ្ងរណាស់សម្រាប់ខ្ញុំ។ ខ្លួនសារភាពថា ខ្លួនពិតជាបានទៅទីតាំងនោះមែន ប៉ុន្តែខ្លួនមិនបានរំលោភសេពសន្ថវៈនោះទេ។ ខ្លួនមិនបានរួមភេទជាមួយឈ្មោះ [redacted] តែ នោះទេ។ ពេលនោះ គេនាំគ្នាឡើងលើផ្ទះ ចំណែកខ្លួននៅក្រោមផ្ទះ។ ខ្លួនមិនដែលមានចិត្តស្រលាញ់ឈ្មោះ [redacted] តែ នោះទេ។ ផ្ទះខ្លួននៅជិតផ្ទះរបស់ឈ្មោះ [redacted] នៅ។ ពេលលេងថ្នាំញៀននោះ គឺពួកយើងនាំគ្នាទៅលេងថ្នាំនៅលើផ្ទះ។ ពេលនោះខ្លួនដឹងថា មានការរួមភេទ ដោយឃើញមានពួកគាត់ឡើងចុះម្នាក់ម្តង។ ចំណែកខ្លួន មិនបានទៅរួមភេទជាមួយជនរងគ្រោះនោះទេ។ ខ្លួនចេះលេងថ្នាំញៀន ប៉ុន្តែខ្លួនមិនចេះលេងស្រីនោះទេ។

-តំណាងអយ្យការធ្វើសេចក្តីសន្និដ្ឋានថាៈ តំណាងអយ្យការសុំរក្សាបទចោទប្រកាន់ទុកជាបានការដដែល និងស្នើសុំឱ្យក្រុមប្រឹក្សាជំនុំជម្រះសម្រេចតម្កល់សាលក្រមលេខ ៩៦ (ឃ) ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០១៨ របស់សាលាដំបូងខេត្តកណ្តាល ទុកជាបានការដដែល។

-មេធាវីការពារសិទ្ធិឱ្យពិរុទ្ធជន ធ្វើសេចក្តីសន្និដ្ឋានថាៈ ដោយហេតុថា កូនក្តីខ្ញុំ មិនបានប្រព្រឹត្តដូចការចោទប្រកាន់នោះទេ ដោយតាមចម្លើយរបស់ឈ្មោះ [redacted] រ័ត្ន ដែលគាត់បានចាប់តាមដីការបស់តុលាការ ហើយគាត់បានប្តឹងទាស់នឹងសាលក្រម ហើយនៅក្នុងពេលសវនាការនោះ ឈ្មោះ [redacted] រ័ត្ន បានឆ្លើយសារភាពថាខ្លួនពិតជាបានរួមភេទជាមួយនឹងជនរងគ្រោះឈ្មោះ [redacted] តែ ពិតប្រាកដមែន ហើយរូបខ្លួនគឺជាអ្នករួមភេទទី៤ ដែលជាអ្នកចុងក្រោយ។ ហើយក្រោយពីនោះមក ពួកគាត់បានត្រឡប់ទៅផ្ទះទាំងអស់គ្នា។ ម្យ៉ាងវិញទៀត តាមចម្លើយរបស់ជនរងគ្រោះ នៅដំណាក់កាលចៅក្រមស៊ើបសួរ គឺគាត់បានបញ្ជាក់ហើយ កូនក្តីរបស់ខ្ញុំបាទមិនបានសុំគាត់រួមភេទនោះទេ និងបានបញ្ជាក់ទៀតថា ចំពោះពាក្យបណ្តឹង គឺប៉ូលីសគាត់ជាអ្នកសរសេរ ហើយឱ្យគាត់ផ្តិតមេដៃលើពាក្យបណ្តឹងនោះ រូបគាត់មិនបានប្តឹងនោះទេ ហើយគាត់សុំដកពាក្យបណ្តឹងវិញ ដោយមិនបានប្តឹងអ្នកទាំងអស់គ្នា និងមិនទាមទារសំណងអ្វីទាំងអស់។ ចុងក្រោយ ខ្ញុំស្នើសុំឱ្យក្រុមប្រឹក្សាជំនុំជម្រះមេត្តាសម្រេចលុបសាលក្រមលេខ ៩៦ (ឃ) ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០១៨ ចោល និងសម្រេចសារជាថ្មីដោយឱ្យកូនក្តីខ្ញុំរួចផុតបទចោទ តាមមាត្រា ២៣៩ និងមាត្រា ២៤០ នៃក្រមព្រហ្មទណ្ឌ និងសុំឱ្យដោះលែងគាត់ចេញ ដើម្បីឱ្យគាត់មើលថែទាំម្តាយចាស់ដែលមានជម្ងឺរាំរ៉ៃផងដែរ។

-សំដីចុងក្រោយរបស់ពិរុទ្ធជនឈ្មោះ [redacted] ម៉ូ ៖ ខ្លួនសុំឱ្យតុលាការសម្រេចលើកលែងទោស។

ក្រោយពីបានស្តាប់ចម្លើយពិរុទ្ធជន

ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ

ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យពិរុទ្ធជន

ក្រោយពីបានស្តាប់សំដីចុងក្រោយរបស់ពិរុទ្ធជន

ក្រោយពីបានពិនិត្យ និងពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

## សាលាដំបូងខេត្តកណ្ដាល

## យល់ឃើញថា

-តាមពាក្យសុំបណ្តឹងទាស់ លេខ ០២៤ ចុះថ្ងៃទី១៤ ខែមីនា ឆ្នាំ២០២២ របស់ពិរុទ្ធជនឈ្មោះ [redacted] ម៉ូ ដែលបានប្តឹងសុំប្តឹងទាស់សាលក្រមកំបាំងមុខលេខ ៩៦ (ឃ) ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០១៨ របស់សាលាដំបូងខេត្តកណ្តាល មានលក្ខណៈត្រឹមត្រូវតាមនីតិវិធីច្បាប់ ដែលអាចឱ្យតុលាការលើកយកមកចាត់ការតាមច្បាប់បាន។

-តាមចម្លើយពិរុទ្ធជនឈ្មោះ [redacted] ម៉ូ បានឆ្លើយថា ខ្លួនសុំប្តឹងទាស់នឹងសាលក្រមកំបាំងមុខលេខ ៩៦ "ឃ" ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០១៨ ព្រោះខ្លួនមិនសុខចិត្តនឹងសេចក្តីសម្រេចដែលមាននៅក្នុងសាល



Scanned with CamScanner

ក្រុមនោះ។ ការផ្ដន្ទាទោសនេះ មានលក្ខណៈធ្ងន់ធ្ងរណាស់សម្រាប់ខ្ញុំ។ ខ្លួនសារភាពថា ខ្លួនពិតជាបានទៅទីតាំងនោះមែន ប៉ុន្តែខ្លួនមិនបានរំលោភសេពសន្ថវៈនោះទេ។ ខ្លួនមិនបានរួមភេទជាមួយឈ្មោះ [redacted] តែ នោះទេ។ ពេលនោះ គេនាំគ្នាឡើងលើផ្ទះ ចំណែកខ្លួននៅក្រោមផ្ទះ។ ខ្លួនមិនដែលមានចិត្តស្រលាញ់ឈ្មោះ ខ្លី តែ នោះទេ។ ផ្ទះខ្លួននៅជិតផ្ទះរបស់ឈ្មោះ [redacted] នៅ។ ពេលលេងថ្នាំញៀននោះ គឺពួកយើងនាំគ្នាទៅលេងថ្នាំនៅលើផ្ទះ។ ពេលនោះខ្លួនដឹងថា មានការរួមភេទ ដោយឃើញមានពួកគាត់ឡើងចុះម្ដាក់ម្ដង។ ចំណែកខ្លួន មិនបានទៅរួមភេទជាមួយជនរងគ្រោះនោះទេ។ ខ្លួនចេះលេងថ្នាំញៀន ប៉ុន្តែខ្លួនមិនចេះលេងស្រីនោះទេ។

-តំណាងអយ្យការសន្និដ្ឋាន បានសន្និដ្ឋានថា ពិតជាមានភស្តុតាងគ្រប់គ្រាន់លើឈ្មោះ [redacted] ម៉ូ បានប្រព្រឹត្តបទ **រំលោភសេពសន្ថវៈ** ពិតប្រាកដមែន និងសុំឱ្យក្រុមប្រឹក្សាជំនុំជម្រះតម្កល់សាលក្រមលេខ ៩៦ (យ) ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០១៨ ទុកជាបានការទាំងស្រុង។

-តាមសេចក្ដីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យពិរុទ្ធជន បានសន្និដ្ឋានឱ្យក្រុមប្រឹក្សាជំនុំជម្រះសម្រេចឱ្យកូនក្ដីខ្លួនរួចផុតបទចោទប្រកាន់។ តុលាការនឹងពិនិត្យពិចារណា។

-តាមចម្លើយរបស់ពិរុទ្ធជនឈ្មោះ [redacted] ម៉ូ, សេចក្ដីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យពិរុទ្ធជន សេចក្ដីសន្និដ្ឋានរបស់តំណាងអយ្យការ និងពិនិត្យឯកសារផ្សេងៗនៅក្នុងសំណុំរឿង ឃើញថា ពិរុទ្ធជនឈ្មោះ [redacted] ម៉ូ បានឆ្លើយបដិសេធថា ខ្លួនមិនបានរំលោភ ឬរួមភេទជាមួយឈ្មោះ [redacted] តែ នោះទេ ប៉ុន្តែតាមចម្លើយឈ្មោះ [redacted] សីលា និងឈ្មោះ [redacted] ឈុនលី បានឆ្លើយថា ក្រោយពេលដែលពួកខ្លួនបានប្រើប្រាស់គ្រឿងញៀនរួចហើយ ពួកខ្លួនទាំងប្រាំនាក់ ពិតជាបានលួងលោមឈ្មោះ [redacted] តែ និងបានរំលោភឈ្មោះ [redacted] តែ បានសម្រេចទាំងប្រាំនាក់មែន។

-មានពិរុទ្ធភាពគ្រប់គ្រាន់ លើពិរុទ្ធជនឈ្មោះ [redacted] ម៉ូ ភេទប្រុស អាយុ ១៦ឆ្នាំ ពីបទ **រំលោភសេពសន្ថវៈ** ប្រព្រឹត្តនៅភូមិព្រែកតាកូវ ឃុំព្រែកតាកូវ ស្រុកខ្សាច់កណ្ដាល ខេត្តកណ្ដាល កាលពីថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១៧ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា ២៣៩ និងមាត្រា ២៤០ នៃក្រមព្រហ្មទណ្ឌ។ ហេតុដូច្នេះ គប្បីតុលាការតម្កល់សាលក្រមលេខ ៩៦ (យ) ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០១៨ ទុកជាបានការដដែល។

## ហេតុដូច្នេះ វិនិច្ឆ័យសេចក្ដី

១-តម្កល់សាលក្រមព្រហ្មទណ្ឌលេខៈ ៩៦ (យ) ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០១៨ របស់សាលាដំបូងខេត្តកណ្ដាល ទុកជាបានការដដែល។

២-សាលក្រមនេះជំនុំជំរះ ជាអសាធារណៈនៅថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០២២ និងប្រកាសជាអសាធារណៈនៅថ្ងៃទី២៤ ខែសីហា ឆ្នាំ២០២២ ចំពោះមុខពិរុទ្ធជនឈ្មោះ [redacted] ម៉ូ និងមេធាវី [redacted] ជាមេធាវីការពារសិទ្ធិឱ្យពិរុទ្ធជន។

ទុកសិទ្ធិឲ្យប្ដឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

| ក្រឡាបញ្ជីសវនាការ | ចៅក្រមប្រឹក្សា | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សាជំនុំជម្រះ |
|---|---|---|---|
| ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា |

[redacted]

"បានចម្លងត្រឹមត្រូវតាមច្បាប់ដើម"

ថ្ងៃពុធ ១២រោច ខែស្រាពណ៍ ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦

កណ្ដាល, ថ្ងៃទី២៤ ខែសីហា ឆ្នាំ២០២២

**ក្រឡាបញ្ជី**

[redacted]

បានឃើញ

**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

[redacted]